# ទំនុកដំកើង ១២០ សេចក្តីអធិស្ឋាននៅចំណោមខ្មាំងសត្រូវ

អ្នកនិពន្ធ រុហ្វ លេភិឡារ

**សេចក្តីផ្តើម** នេះគឺជាទំនុកច្រៀងតាមថ្នាក់ទីមួយនៃទំនុកច្រៀងតាមថ្នាក់ទាំងដប់ប្រាំ *(ទំនុកដំកើង ១២០-១៣៤)* (សូមមើលសេចក្តីនែនាំ)។ ទំនុកដំកើងនេះចាប់ផ្តើមអនុក្រមនៃទំនុកដំកើងនេះនៅក្នុងទឹកដីឆ្ងាយមួយ *(ខ. ៥-៦)* ដូច្នេះ យើងចូលរួមពួកអ្នកធម្មយាត្រាដែលពួកគេចាប់ផ្តើមដំណើរទៅកាន់យេរូសាឡឹម។

**ខ. ១** *កាលខ្ញុំមានសេចក្តីវេទនា នោះបានអំពាវនាវដល់ព្រះ យេហូវ៉ា ហើយទ្រង់បានតបមកខ្ញុំ។* ខនេះបង្ហាញអំពីផ្ទៃរឿងមួយនៅក្នុងកណ្តូទំនុកដំកើងគឺ សេចក្តីអធិស្ឋានទៅកាន់ព្រះយ៉ាវេនៅពេលមានទុក្ខលំបាក *(សូមមើល សុភាសិត ២០:២២ រ៉ូម ១២:១៩)* ហើយនិងសេចក្តីកំសាន្តចិត្តដែលមកពីព្រះដែលឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើង។ ដូច្នេះ ទំនុកដំកើងនេះដូចគ្នានឹងទំនុកដំកើង ៤២/៤៣, ៨៤ និង៩០ដែរ។ ទំនុកដំកើងទាំងនេះគឺនៅដើមដំបូងនៃអនុក្រមនៃទំនុកដំកើងហើយបង្ហាញអំពីសេចក្តីត្រូវការមួយ។

**ខ. ២** *សេចក្តីវេទនា* ដែលមកពីពាក្យរបស់មនុស្សទុច្ចរិតផ្ទុយនឹងទំនុកដំកើង១១៩ដែលពិពណ៌នាអំពីសិរីភាពដែលមកពីព្រះបន្ទូលរបស់ព្រះ។ អ្នកនិពន្ធនៃទំនុកដំកើង១២០មិនឈ្លោះជាមួយមនុស្សដែលមានបបូរមាត់ដ៏កំភូតទេ ប៉ុន្តែមើលទៅឯព្រះដើម្បីឲ្យទ្រង់សង្គ្រោះគាត់វិញ ហើយគាត់ចងចាំថាព្រះបានឆ្លើយតបសេចក្តីអធិស្ឋានរបស់គាត់ *(ខ. ១)*។

**ខ. ៤** *រងើកភ្លើងឈើដង្កោ។* តួនៃឈើដង្កោផ្តល់ឲ្យនូវឈើរីតដែលអាចធ្វើជាធ្យូងយ៉ាងល្អ។ ថ្វីបើមនុស្សទុច្ចរិតនាំសេចក្តីវេទនាមកលើមនុស្សសុចរិតតាមរយៈអណ្តាតដែលបញ្ឆោតរបស់ពួកគេ ក៏ព្រះនឹងនាំសេចក្តីវេទនាកាន់តែធំជាងមកលើមនុស្សទុច្ចរិតតាមរយៈការវិនិច្ឆ័យរបស់ទ្រង់។ អ្នកនិពន្ធមិនត្រូវសងសឹកឡើយ ប៉ុន្តែទុកឲ្យព្រះវិនិច្ឆ័យវិញ។ *ព្រួញ (៤)* ដែលតម្រង់ដោយជំនាញរបស់អ្នកចំបាំងត្រូវតែចាក់ចំគោលដៅរបស់វា៖ ការដាក់ទោសនឹងធ្លាក់ទៅកន្លែងណាដែលសមនឹងទទួល ប៉ុន្តែនៅពីក្រោយវាមានភ្លើងកំពុងឆេះដែលជាសំណងយុត្តិធម៌របស់ព្រះមួយអង្គដែលស្អប់អំពើបាប។ ប៉ុន្តែដោយសារតែគាត់ទុកសកម្មភាពនេះឲ្យព្រះអម្ចាស់ អ្នកនិពន្ធទំនុកដំកើងរស់នៅក្នុងពិភពលោកមួយដែលមិនអាចផ្តល់សន្តិភាពបានទេ *(៥-៧)*។

**ខ. ៥-៦** *មែសេក* នៅទិសខាងជើងឆ្ងាយ *(លោកុប្បត្តិ ១០:២)* និង*កេដារ (*យេរេមា ២:១០*)* នៅក្នុងទីរហោស្ថានអារ៉ាប់គឺនៅឆ្ងាយពីគ្នា ដូច្នេះកន្លែងទាំងពីរមិនអាចជាកន្លែងដែលអ្នកនិពន្ធរស់នៅ។ កន្លែងទាំងពីរនេះផ្តល់រូបអំពីការនៅឆ្ងាយពីផ្ទះ នៅក្នុងពិភពលោកដែលបះបោរដែលមិនស្គាល់ព្រះ។ ដូច្នេះ ឥឡូវនេះច្បាស់ហើយពីមូលហេតុដែលអ្នកនិពន្ធស្ថិតក្នុងស្ថានភាពមួយដែលមនុស្សនិយាយកំភូតប្រឆាំងនឹងគាត់។

**ខ. ៧** ទោះបីជាអ្នកនិពន្ធរស់នៅក្នុងពិភពលោកបះបោរ ក៏គាត់នឹងរស់នៅដោយសន្តិភាព *(ប្រៀបធៀប ១០៩:៤)* ហើយចែកចាយសន្តិភាពដែលគាត់មាន ប៉ុន្តែពិភពលោកគឺជាទីកន្លែងងងឹតដែលមិនទទួលស្គាល់គាត់នោះទេ។

**ការអនុវត្ត**

បទគម្ពីរនេះបង្ហាញអំពីភាពមិនត្រូវគ្នានៃពន្លឺនិងភាពងងឹត។ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនគ្រីស្ទបរិស័ទនៅក្នុងស្ថានភាពនេះឲ្យជៀសវាងកំហុសពីរ៖ ទីមួយ ចូលរួមឬតាមគេ *(២កូរិនថូស ៦:១៤..., ១យ៉ូហាន ២:១៥...)* ហើយទីពីរ សំអប់ *(រ៉ូម ១២:១៤-២១)*។ ដោយការងាកបែរមកឯព្រះដើម្បីសេចក្តីសង្គ្រោះ អ្នកនិពន្ធទំនុកដំកើងនេះជៀសវាងកំហុសទាំងពីរនេះ។ ម្តងទៀត គំរូដ៏ល្អបំផុតសំរាប់ការនេះនៅក្នុងព្រះគម្ពីរគឺការយាងទៅឯឈើឆ្កាងរបស់ព្រះយេស៊ូវ។ ទ្រង់ស្តាប់បង្គាប់ព្រះវរបិតា ហើយមិនបានបង្ហាញសំអប់ចំពោះពួកខ្មាំងសត្រូវរបស់ទ្រង់ដែលបាននិយាយកំភូតប្រឆាំងនឹងទ្រង់ដែលបាននាំទៅដល់ការសុគតរបស់ទ្រង់នោះទេ ប៉ុន្តែទ្រង់បានអំពាវនាវដល់ព្រះវរបិតានៅក្នុងសេចក្តីវេទនារបស់ទ្រង់វិញ។

**សំនួរឆ្លុះបញ្ចាំង**

តើអ្នកឆ្លើយតបយ៉ាងដូចម្តេចនៅពេលមនុស្សដែលមិនស្គាល់ព្រះនិយាយប្រឆាំងនឹងអ្នក?

តើបទគម្ពីរនេះលើកទឹកចិត្តអ្នកដោយរបៀបណា?